# សង្គមស៊ីវិលអំពាវនាវឱ្យរដ្ឋាភិបាលទម្លាក់ចោលគម្រោងត្រួតពិនិត្យអ្នកប្រើអ៊ីនធឺណិត

- លោក សេង ថៃ
- ១៨ កុម្ភៈ ២០២១
- ម៉ោង ២២:០២



បុរសម្នាក់កាន់ទូរសព្ទរបស់ខ្លួនដែលកំពុងតែដំណើរការចូលទៅប្រើប្រាស់កម្មវិធីបណ្ដាញសង្គមហ្វេសប៊ុក។ (ហេង វិចិត្រ)

អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ រួមជាមួយសហគមន៍ប្រជាពលរដ្ឋចំនួន៤៦ស្ថាប័ន បានអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជាទម្លាក់ចោលអនុក្រឹត្យស្តីពី «**ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ**»ដោយអះអាងថា អនុក្រឹត្យនេះបំពានសិទ្ធិអ្នកប្រើអ៊ីនធឺណិត។
សេចក្តីថ្លែងការណ៍របស់អង្គការនិងសហគមន៍ជាតិចំនួន៤៥ នៅថ្ងៃនេះ បានចាត់ទុកថា អនុក្រឹត្យនេះបានបំពានកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ដោយបំពានមកលើសិទ្ធិតាមបណ្តាញអ៊ីនធឺណិត និងក្រៅប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា ជាពិសេសសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិឯកជនភាព ជាដើម។

រដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី១៧ ខែកុម្ភៈ ទើបតែបានផ្សព្វផ្សាយអនុក្រឹត្យ ស្តីពី «**ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ**»។ អនុក្រឹត្យដែលមាន១១ជំពូក និង ២០មាត្រានេះ ត្រូវបានរៀបចំឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ហើយត្រូវបានចុះហត្ថលេខាដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១។ អនុក្រឹត្យនេះតម្រូវឱ្យមានការផ្តល់របាយការណ៍ពីអ្នកផ្គត់ផ្គង់អ៊ីនធឺណិតដល់រដ្ឋាភិបាល និងផ្តល់ការសហការក្នុងការចូលរួមបង្ក្រាបសកម្មភាពដែលប៉ះពាល់ដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សង្គមជាដើម។
យ៉ាងណាក្តី ក្នុងសេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិលទាំង៤៥ស្ថាប័ន បានចាត់ទុកថា អនុក្រឹត្យនេះនឹងសម្របសម្រួលឱ្យមានការឃ្លាំមើលនិងតាមដានសកម្មភាពតាមអ៊ីនធឺណិត ផ្តល់សិទ្ធិអំណាចដល់ការតាមដាន និងការត្រួតពិនិត្យការប្រាស្រ័យទាក់ទងតាមប្រព័ន្ធឌីជីថល និងជួយដល់ការប្រមូល ការរក្សាទុក និងចែករំលែកទិន្នន័យផ្ទាល់ខ្លួន ដែលជាមូលដ្ឋាននាំឱ្យមានការគំរាមកំហែងដល់សិទ្ធិឯកជនភាព សេរីភាពខាងការបញ្ចេញមតិ និងទទួលបានព័ត៌មាន។ សេចក្តីថ្លែងការណ៍បន្តថា អនុក្រឹត្យនេះមានគោលបំណងដាក់ឱ្យចរាចរអ៊ីនធឺណិតអន្តរជាតិទាំងអស់នៅក្រោមអំណាចអាជ្ញាធរតែមួយ ដែលធ្វើឱ្យរដ្ឋាភិបាលកាត់បន្ថយសកម្មភាពអ៊ីនធឺណិតក្នុងប្រទេសដែលមកពីអន្តរជាតិប្រកបដោយប្រសិទ្ធភាពថែមទៀត។

ក្រៅពីអង្គការសង្គមស៊ីវិលទាំង៤៥ស្ថាប័នខាងលើនេះ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ Human Right Watch ក៏បានចេញសេចក្តីថ្លែងការណ៍ដាច់ដោយឡែកនៅថ្ងៃនេះ ដោយបានចាត់ទុកថា ការបង្កើត "ច្រកទ្វារអ៊ីនធឺណិតជាតិ" របស់រដ្ឋាភិបាលកម្ពុជានេះ នឹងអនុញ្ញាតឱ្យរដ្ឋាភិបាលបង្កើនការឃ្លាំមើលនិងការត្រួតពិនិត្យតាមអ៊ីនធឺណិតទៅលើអ្នកប្រើប្រាស់ ដែលនឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងឯកជនភាពជាដើម។

តាមរយៈសេចក្តីថ្លែងការណ៍នេះ លោក Phil Robertson នាយករងប្រចាំអាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានលើកឡើងថា លោកនាយករដ្ឋមន្រ្តី ហ៊ុន សែន បានចាប់ផ្តើមសកម្មភាព ប្រឆាំងនឹងសេរីភាពអ៊ីនធឺណិត និងពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា តាមរយៈការពង្រីកការគ្រប់គ្រងរបស់រដ្ឋាភិបាលលើអ៊ីនធឺណិតក្នុងប្រទេស។ លោកបានអំពាវនាវឱ្យរដ្ឋាភិបាលបរទេស ក្រុមហ៊ុនបច្ចេកវិទ្យា ក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធឺណិត និងវិស័យឯកជនដទៃទៀត ចូលរួមជំរុញឱ្យរដ្ឋាភិបាលដកអនុក្រឹត្យនេះវិញជាបន្ទាន់។

អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា លោក ផៃ ស៊ីផាន បានមានប្រសាសន៍ថា នេះគឺជាសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតច្រកទ្វារអ៊ីនធឺណិត ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់សង្គម។ អ្នកនាំពាក្យរដ្ឋាភិបាលរូបនេះបានពន្យល់ថា គំនិតផ្តួចផ្តើមនេះនឹងជួយគ្រប់គ្រងអ្នកផ្តល់សេវាអ៊ីនធឺណិតដែលមានភាពមិនប្រក្រតី៕

ព័ត៌មានលម្អិតសូមចូលទៅកាន់៖ https://vodkhmer.news/2021/02/18/ngos-appeal-to-cambodia-government-drop-of-national-internet-gateway/?fbclid=IwAR1WTeQxQPjbjCWXZyf-XWi-ZKu7JuH_9_tiwadUwUiCjqb1mCwJOTmat08